កម្ពុជា-សង្គម

# ១៤ឆ្នាំនៃការសម្លាប់លោក ឈុត វុទ្ធី៖ ក្រុមគ្រួសារនិងសង្គមស៊ីវិលទាមទារឲ្យអាជ្ញាធររករកមុខឃាតករនៅក្រោយខ្នង

ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៦នេះ ជាខួប ១៤ឆ្នាំ នៃការបាញ់សម្លាប់លើអ្នកការពារព្រៃឈើដ៏ល្បីឈ្មោះ គឺលោក ឈុត វុទ្ធី។ ក្នុងឆ្នាំនេះ បណ្ដាអង្គការសង្គមស៊ីវិលមិនបានធ្វើពិធីជួបជុំបែបសាសនាណាមួយ ដើម្បីរម្លឹកដល់វិញ្ញាណក្ខន្ធលោក ឈុត វុទ្ធី ឡើយ។ ប៉ុន្តែពួកគេបានចេញសាររៀងៗខ្លួនតាមបណ្ដាញសង្គម បន្តទាមទារឲ្យរដ្ឋាភិបាលបើកការស៊ើបអង្កេតនិងរកមុខឃាតករនៅពីក្រោយខ្នងនៃការបាញ់សម្លាប់លើលោក ឈុត វុទ្ធី។

ចុះផ្សាយនៅថ្ងៃ៖ 26/04/2026 - 11:42 កែប្រែថ្ងៃទី៖ 26/04/2026 - 11:45 ១២ នាទី

ស្ដាប់ - ០២:៤៦



ដោយ៖ ជួប នរក្សា

«មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមអំពាវនាវដល់អាជ្ញាធរកម្ពុជាឲ្យដោះស្រាយ និងបញ្ចប់វប្បធម៌និទណ្ឌភាព តាមរយៈស្ថាប័នដែលឯករាជ្យ និងមិនលម្អៀងមួយ និងនាំយកអ្នកដែលទទួលខុសត្រូវរាល់ករណីសម្លាប់ក្រៅប្រព័ន្ធតុលាការទាំងអស់ ព្រមទាំងករណីអ្នកការពារសិទ្ធិមនុស្សដូចជាលោក ឈុត វុទ្ធី ផងដែរ មកផ្ដន្ទាទោសតាមច្បាប់។» នេះគឺសាររបស់លោក សេង សុវឌ្ឍនា នាយកប្រតិបត្តិមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលត្រូវបានបង្ហោះនៅក្នុងឱកាសខួប ១៤ឆ្នាំនៃការបាញ់សម្លាប់លើសកម្មជនការពារព្រៃឈើដ៏ល្បីល្បាញលោក ឈុត វុទ្ធី។

ផ្សាយពាណិជ្ជកម្ម

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានស្រង់សម្ដីកូនប្រុសលោក ឈុត វុទ្ធី គឺលោក ឆឹយ ឧត្ដមរស្មី ដែលបានរៀបរាប់ថា អស់រយៈពេល១៤ឆ្នាំមកនេះ ក្រុមគ្រួសាររបស់លោកនៅមិនទាន់ទទួលបានយុត្តិធម៌។ ក្នុងនាមជាកូនប្រុសរបស់លោក ឈុត វុទ្ធី លោក ឆឹយ ឧត្ដមរស្មី នៅតែទាមទារឲ្យមានការស៊ើបអង្កេតដោយឯករាជ្យ និងតម្លាភាព ដើម្បីផ្ដល់យុត្តិធម៌ពិតប្រាកដដល់គ្រួសាររបស់លោក។ បើតាមលោក ឧត្ដមរស្មី មកដល់ពេលនេះ មេគំនិតដែលនៅពីក្រោយខ្នងឃាតករ ដែលបាញ់សម្លាប់ឪពុករបស់លោក នៅមិនទាន់បានចាប់ខ្លួនយកមកផ្ដន្ទាទោសតាមច្បាប់នៅឡើយ។



ក្រៅពីអង្គការទាំងពីរខាងលើ អង្គការមាតាធម្មជាតិឯណោះវិញ ក៏បានសរសេរថា រយៈពេល ១៤ឆ្នាំ បានកន្លងផុតទៅហើយ ប៉ុន្តែយុត្តិធម៌សម្រាប់លោក ឈុត វុទ្ធី នៅតែមិនឃើញមានពន្លឺ។ អង្គការដែលរិះគន់រដ្ឋាភិបាលមិនសំចៃមាត់មួយនេះ បានចោទជាសំណួរថា តើរដ្ឋាភិបាលមានឆន្ទៈពិតប្រាកដ ក្នុងការស្វែងរកយុត្តិធម៌ជូនលោក ឈុត វុទ្ធី ដែរឬទេ? ឬក៏សំណុំរឿងនេះត្រូវទុកឲ្យស្ងៀមស្ងាត់ និងត្រូវបំភ្លេចចោល?។

សូមជម្រាបថា កាលពី១៤ ឆ្នាំមុន ពោលនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ លោក ឈុត វុទ្ធី ត្រូវមន្ត្រីកងរាជអាវុធហត្ថម្នាក់ឈ្មោះ អ៊ិន រតនា បាញ់សម្លាប់ត្រង់ចំណុចវាលបី ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ខណៈលោក និងអ្នកសារព័ត៌មានពីររូបផ្សេងទៀតរបស់កាសែត The Cambodia Daily កំពុងចុះស៊ើបអង្កេតរឿងបទល្មើសព្រៃឈើខុសច្បាប់នៅក្នុងតំបន់ភ្នំក្រវាញ។ តែបន្ទាប់មកឈ្មោះ អ៊ិន រតនា ក៏បានបាញ់សម្លាប់ខ្លួនឯងនៅពេលជាមួយគ្នានោះ។ នេះជាការអះអាងរបស់រដ្ឋាភិបាលកម្ពុជាកន្លងមក៕